ការបង្ហាញចម្ងាក់ព្រះឥសូរនៅសម័យមុនអង្គរ

ព្រះឥសូរ គឺជាទេពធំជាងគេនៅក្នុងព្រហ្មញ្ញសាសនា។ ទ្រង់មានព្រះនាមច្រើនណាស់ តែព្រះនាមដែលគេច្រើនស្គាល់មានដូចជា សិវ ហរ មហេសូរ រុទ្រ ឧគញរ អឃោរ ភៃរវ ។ល។ ព្រះឥសូរមានព្រះនេត្របី មានចំណិតព្រះចន្ទ្រលើផ្ទួងសក់ ព្រះហស្តពីរ បួនប្រាំបី និងដប់ ហើយភាគច្រើនតែងមានយានជំនិះជាសត្វគោនន្ទិ និងពេលខ្ទះជិះសត្វផ្សេងៗទៀតទៅតាមរូបភាពរបស់ទ្រង់។ នៅក្នុងព្រះហស្តរបស់ព្រះឥសូរមានកាន់ថូរ ស្គរ ផ្គាំ លលាដ៏ក្បាល ត្រីសូល៍ និងខ្សែ។ ទ្រង់មានតួនាទីបង្កើតលោក និងបំផ្ទាញលោកចាស់ ដើម្បីបង្កើតលោកថ្មីមួយទៀត។[9]

នៅសម័យមុនអង្គរ នាស.វ.ទី៧-៨ ខ្មែរនិយមធ្ងាក់រូបព្រះលិង្គតំណាងឲ្យព្រះឥសូរ (រូបលេខ១) និងពុំសូវនិយមធ្ងាក់រូបព្រះឥសូរក្នុងទម្រង់រូបភាពដូចមនុស្សទេ ពោល គឺមានតិចតួចបំផុត។[10] ក្រៅពីនេះ នៅសម័យមុនអង្គរខ្មែរបានធ្ងាក់រូបត្រីសូល៍ និងព្រះបាទតំណាងឱ្យព្រះឥសូរក៏មាន (រូបលេខ២-៣)។ ដោយឡែក ចម្ងាក់ព្រះឥសូរដែលបង្ហាញទម្រង់ដូចមនុស្សនៅស.វ.ទី៧ គេបង្ហាញពីរប្រភេទ។ ប្រភេទទី១ គឺចម្ងាក់ព្រះឥសូរជិះលើយានជំនិះជាសត្វផ្សេងៗ និងប្រភេទទី២ គឺចម្ងាក់ព្រះឥសូរក្នុងទម្រង់ជាឥសី។

នៅក្នុងសិល្ប:ខ្មែរនាស.វ.ទី៧ យ៉ាងតិចក៏មានចម្ងាក់ព្រះឥសូរចំនួនបួន ដែលសិល្បករធ្ងាក់ឡើងដោយមានជិះលើសត្វផ្សេងៗ។ រូបភាពទី១ យើងសូមបង្ហាញអំពីចម្ងាក់មួយនៅលើផ្តែរទ្វារដែលរកឃើញនៅប្រាសាទភ្នំធំ (ខ្ទះហៅភ្នំជើងព្រៃ) (រូបលេខ២) ដែលស្ថិតនៅស្រុកជើងព្រៃ ខេត្តកំពង់ចាម។ ចម្ងាក់នេះគេធ្ងាក់នៅលើក្បាច់រាងរង្វង់ (មេដាយ៉ុង) ស្ថិតនៅចំកណ្តាលផ្តែរដោយមានយានជំនិះជិះលើសត្វតោ។ ជាទូទៅ ការបង្ហាញចម្ងាក់ព្រះឥសូរមានយានជំនិះសត្វតោ នៅសម័យមុនអង្គរ យើងទំនងពុំធ្ងាប់ឃើញមាននៅកន្ទែងផ្សេងនោះទេ។ ប៉ុន្តែ នៅសម័យអង្គរ ការបង្ហាញបែបនេះយើងជួបច្រើនកន្ទែងពោល ដូចជានៅប្រាសាទព្រះធាតុបាស្រី (ខេត្តកំពង់ចាម) ប្រាសាទភិមាយ (ប្រទេសថៃបច្ចុប្បន្ន) ចម្ងាក់នៅពើងគំនូរ ភ្នំគូលែន (ខេត្តសៀមរាប)។ ម្ចោ៉ះហើយ យើងអាចសន្និដ្ឋាន

[9] Roveda 2005: 146; Cornelia & Buitenen 1978: 147-216.

[10] Bhattacharya 1961: 82.

បានថាចម្លាក់នៅចំកណ្តាលផ្នែរទ្វារមួយស.រ.ទី៧នៅភ្នំធំ ទំនងជារូបព្រះឥសូរមានយានជំនិះសត្វគោ។ រូបភាពទី២ ចម្លាក់ព្រះឥសូរមានយានជំនិះសត្វគោនន្ទិធ្លាក់លើផ្នែរទ្វារប្រាសាទទួលព្រះធាតុ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ហើយសព្វថ្ងៃរក្សាទុកនៅសារមន្ទីរជាតិកម្ពុជា (រូបលេខ៥)។ នៅលើផ្នែរទួលព្រះធាតុ គេធ្លាក់ព្រះឥន្ទ្រគង់នៅលើដំរីព្ធ្ងវ៌តនៅចំកណ្តាល រូបព្រះឥសូរគង់នៅលើគោនន្ទិនៅខាងធ្វេង និងមានរូបព្រាហ្មណ៍ម្នាក់លត់ជង្គង់ខាងស្តាំព្រះឥន្ទ្រ។[៣] ចម្លាក់ព្រះឥសូរគង់នៅខាងធ្វេងព្រះឥន្ទ្ររបៀបនេះ យើងកម្រឃើញមានណាស់នៅក្នុងសិល្ប:ខ្មែរ ហើយលោក Lunet De Lajonquière និងលោក Henri Parmetier យល់ថាទំនងជារូបភាពបង្ហាញពីព្រះរាជពិធីថ្វាយព្រះភ្លើង។[៤] រូបភាពទី៣ ចម្លាក់ព្រះឥសូរមានយានជំនិះសត្វគោនន្ទិ ធ្លាក់នៅលើផ្នែរទ្វាររកឃើញនៅស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង (រូបលេខ៦) ហើយសព្វថ្ងៃរក្សាទុកនៅសារមន្ទីរជាតិភ្នំពេញ។ ចម្លាក់ព្រះឥសូរនេះ គេធ្លាក់នៅកណ្តាល ដែលខាងធ្វេងមានព្រះវិស្ណុ និងខាងស្តាំមានព្រះព្រហ្ម។ ចម្លាក់របៀបនេះគេច្រើនហៅថា "ត្រីមូតិ៍" ហើយប្រពៃណីធ្លាក់បែបនេះមានបន្តនៅសម័យអង្គរច្រើន។ រូបភាពទី៤ ចម្លាក់ព្រះឥសូរមានយានជំនិះសត្វគោនន្ទិ ធ្លាក់នៅចំកណ្តាលផ្នែកខាងលើ នៃផ្នែរទ្វារវត្តប្រាសាទ ក្នុងភូមិប្រាសាទ ឃុំជ្រៃឃ្មុំ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង (រូបលេខ៧) ហើយសព្វថ្ងៃរក្សាទុកនៅសារមន្ទីរខេត្តព្រៃវែង។ ផ្នែរទ្វារនេះមានទម្រង់សិល្ប:រចនាបថសំបូរព្រៃគុក ស.រ.ទី៧ ដោយមានផ្នែកខាងក្រោមធ្លាក់បង្ហាញអំពីពិធីស្រោចទឹក។ នៅផ្នែកខាងក្រោម យើងឃើញរូបព្រះនាងលក្ស្មីគង់នៅផ្កាឈូកចំពាក់កណ្តាល ដែលជាតួអង្គត្រូវពួកព្រាហ្មណ៍ស្រោចទឹកជូន ហើយនៅខាងចុងផ្នែកខាងធ្វេងយើងឃើញមានចម្លាក់ព្រះព្រហ្ម និងព្រះវិស្ណុ។ អ្វីគួរចាប់អារម្មណ៍នោះគឺចម្លាក់គោនន្ទនៅលើផ្នែរទ្វារវត្តប្រាសាទមានលក្ខណ:ដូចផ្នែរទ្វារទួលព្រះធាតុ ហើយរូបគោគេធ្លាក់បែរមុខចំ ដែលខុសពីផ្នែរទ្វារមកពីស្វាយជ្រុំ ខេត្តស្វាយរៀង គេធ្លាក់រូបគោនន្ទិចំហៀង។

ចំណែក ចម្លាក់ព្រះឥសូរក្នុងទម្រង់ជាឥសី យើងឃើញមានធ្លាក់នៅលើផ្នែរទ្វារប្រាសាទសណ្ដាន់ (ត្ជម N.21) នៃតំបន់ប្រាសាទសំបូរព្រៃគុក (រូបលេខ៨)។ ចម្លាក់នេះ

[៣] Lajonquière 1902: 72-73; Parmentier 1927: 128; Bénisti 1971: 128.

[៤] Lajonquière 1902: 72-73; Parmentier 1927.

ធ្លាក់ឡើងនៅក្នុងក្បាច់មេដាយ៉ុងចំពាក់កណ្តាលផ្តែរ ក្នុងកាយវិការលើកព្រះហស្តទាំងពីរ ជាក់គងលើគ្នាដូចកាយវិការសមាធិ។ អ្នកស្រាវជ្រាវខ្លះយល់ថា រូបនេះជាព្រះពុទ្ធអង្គ កំពុងសមាធិ ប៉ុន្តែលោកស្រី Mireille Bénisti បានសិក្សាឡើងវិញ និងបានឱ្យសេចក្តីសន្និដ្ឋានថាជាចម្លាក់ព្រះឥសូរក្នុងទម្រង់យោគិសូរ ពោល គឺឥសូរក្នុងទម្រង់ជាឥសីតាំងសិល្ប៍ក្នុងព្រៃ។[៥] ចម្លាក់រៀបនេះ យើងធ្លាប់ជួបនៅលើផ្តែរទួលក្តីក្នុង ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ប៉ុន្តែសព្វថ្ងៃផ្តែរទ្វារនេះបានបាត់បង់ពីទីតាំងដើមទៅហើយ។[៦] ក្រៅពីនេះ យើងធ្លាប់ឃើញមានចម្លាក់ឥសីធ្លាក់នៅលើក្បាច់វិមានអណ្តែត តួប៉ម N11 និង តួប៉ម N1 នៃក្រុមខាងជើងតំបន់ប្រាសាទសំបូរព្រៃគុក (រូបលេខ ៩-១០)។[៧]

ជារួមមក យើងសង្កេតឃើញថាកស្តុតាងការគោរពព្រះឥសូរនៅកម្ពុជានាសម័យមុនអង្គរ យើងច្រើនឃើញគេនិយមសាងសង់ជាព្រះលិង្គជាតំណាងឲ្យព្រះឥសូរ។ ចំណែករូបភាពព្រះឥសូរក្នុងទម្រង់រូបភាពដូចមនុស្ស និងទម្រង់ជាឥសីមានមិនច្រើននោះទេ។

ឯកសារយោង

Bénisti, Mireille

- 1966, "Notes d'iconographie khmère : III. Au sujet d'un linteau de Sambor Prei Kuk", *BEFEO*, Tome 53, Paris
- 1971, "Notes d'iconographie khmère : III. Au sujet d'un linteau de Sambor Prei Kuk", *BEFEO*, Tome 58, Paris
- 1974, Recherches sur le premier art khmer, VI. Linteaux inéits et linteaux méconnus, *Art Asiatique*, Tome 30, Paris

Bhattacharya, Kamaleswar

1961, *Les religions brahmaniques dans l'ancien Cambodge d'après l'épigraphie et l'iconographie*, EFEO, Paris

Dimmit, Cornelia & Buitenen, J.A.B

1978, *Classical Hindu Mythology*, USA

Lunet De Lajonquière

1902, *Inventaire descriptive des monuments du Cambodge*, Tome I, Paris

Parmentier, Henri

1927, *L'Art Khmer Primitif*. Paris: G. Van Oest.

Roveda, Victorio

2005, "*Image of the gods*", Bangkok

[៥] Bénisti 1966: 74-75.

[៦] Bénisti 1974: 168.

[៧] Chen Chanrathana 2006: 232-233.

រូបលេខ១៖ លិង្គ ស.វ.ទី៧ រកឃើញនៅសំបូរព្រៃគុក

រូបលេខ២៖ ផ្ទាំងថ្មបង្ហាញរូបត្រីសូល៍ រកឃើញនៅខេត្តស្ទឹងត្រែង

រូបទី៣៖ សិវបាទ រកឃើញនៅប្រាសាទកំពង់ព្រះ

រូបលេខ៤៖ ចម្លាក់ព្រះឥសូរគង់នៅលើសត្វគោ រកឃើញនៅប្រាសាទភ្នំធំ (ប្រភព៖ ដែ ឈៀងម៉ង)

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

រូបលេខ៥៖ ចម្លាក់ព្រះឥសូរគង់នៅលើសត្វគោនន្ទ រកឃើញនៅប្រាសាទទួលព្រះធាតុ

រូបលេខ៦៖ ចម្លាក់ព្រះឥសូរគង់នៅលើសត្វគោនន្ទ រកឃើញនៅស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង

រូបលេខ៧៖ ចម្លាក់ព្រះឥសូរគង់នៅលើសត្វគោនន្ទ រកឃើញនៅវត្តប្រាសាទ ខេត្តព្រៃវែង (ប្រភព៖ សរ សុ

រូបលេខ៨៖ ចម្លាក់យោគិស្វរ ឬព្រះឥសូរទម្រង់ជាឥសី រកឃើញនៅប្រាសាទសណ្ឋាន់ (សំបូរព្រៃគុក)

រូបទី៩-១០៖ ចម្លាក់យោគិស្វរ ឬព្រះឥសូរទម្រង់ជាឥសី នៅតំបន់ប្រាសាទសំបូរព្រៃគុក